THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Tony B. Watlington Sr., Ed.D.**
Superintendent

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

**សិស្សថ្នាក់ទី ៨ ដល់ ទី ១២ នឹងចូលរួមក្នុង ការប្រឡង Keystone (ឃីស្តូន) នៅចន្លោះថ្ងៃទី ១៣ ខែ ឧសភា និងថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០២៤។**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ត្រូវបានដឹកនាំដោយ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង លក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ Goals & Guardrails របស់ក្រុមប្រឹក្សាអប់រំ។ គោលដៅរបស់ក្រុមប្រឹក្សាភិបាលគឺចង់ឃើញសិស្សគ្រប់រូបរៀនបានតាមកម្រិត ឬខ្ពស់ជាងកម្រិតថ្នាក់ ក្នុងផ្នែកពិជគណិត ជីវវិទ្យា និងអក្សរសាស្ត្រ ហើយបញ្ចប់ការសិក្សាដោយមានការត្រៀមខ្លួនជាស្រេចសម្រាប់មហាវិទ្យាល័យ និងអាជីព។ ការប្រឡង Keystone **គឺជាតម្រូវការសម្រាប់ការបញ្ចប់ការសិក្សាពីវិទ្យាល័យ** នៅរដ្ឋផិនស៊ីលវេនញ៉ា ហើយមានសារៈសំខាន់សម្រាប់ការយល់ដឹងអំពីការរីកចម្រើនក្នុងការសិក្សារបស់កូនលោកអ្នក។ ពិន្ទុក៏ផ្តល់ឱ្យគ្រូបង្រៀននូវព័ត៌មានដ៏មានតម្លៃ ដើម្បីគាំទ្រដល់ការរៀនសូត្ររបស់សិស្សម្នាក់ៗ ហើយអនុញ្ញាតឱ្យក្រសួងអប់រំកែលម្អកម្មវិធីសិក្សា និងការបង្ហាត់បង្រៀន ជាបន្ត។

ការប្រឡង Keystone ក្នុងផ្នែកពិជគណិត ជីវវិទ្យា និងអក្សរសិល្ប៍ ត្រូវបានកំណត់ដោយរដ្ឋ។ តាមធម្មតា សិស្សប្រឡងនៅនិទាឃរដូវ នៅពេលដែលពួកគេជិតបញ្ចប់វគ្គសិក្សាពិជគណិត ១ ភាសាអង់គ្លេស ២ និង/ឬ ជីវវិទ្យា។ សាលានីមួយៗត្រូវតែមានសិស្សចំនួន 95% ប្រឡង។ ប្រសិនបើសាលារៀនមានការចូលរួមតិចជាង 95% នោះពិន្ទុនៃការប្រឡងរបស់រដ្ឋសម្រាប់សាលាត្រូវរងផលប៉ះពាល់អវិជ្ជមាន។

**ក្នុងអំឡុងពេលនៃការប្រឡង Keystone ជាការសំខាន់ខ្លាំងណាស់ដែលសិស្សានុសិស្សទៅរៀនរាល់ថ្ងៃ ហើយបន្តចុះឈ្មោះនៅសាលាបច្ចុប្បន្នរបស់ពួកគេ។** ដោយមូលហេតុនេះ សំណើផ្លាស់ប្តូរសិស្សនឹងត្រូវផ្អាកសិន រហូតដល់ចុងបញ្ចប់នៃរយៈពេលប្រឡង ដោយមានករណីលើកលែងតិចតួចបំផុត។

លោកអ្នកអាចស្វែងយល់បន្ថែមអំពីការប្រឡង Keystone ដោយប្រើបណ្តាញតភ្ជាប់ (links) ខាងក្រោមនេះ។ សាលារបស់កូនលោកអ្នកក៏នឹងផ្ញើព័ត៌មាននេះទៅលោកអ្នកផងដែរ ហើយព័ត៌មាននេះក៏អាចឃើញនៅលើ **គេហទំព័រ Keystone Keystone website** របស់យើង។

- **Keystone Parent Guide**: ការពិពណ៌នាទូទៅអំពី Keystone ជាមួយនឹង បណ្តាញតភ្ជាប់ (links) ទៅកាន់ធនធានសម្រាប់មាតាបិតារបស់ក្រសួងអប់រំ

- **Frequently Asked Questions**: ទំព័រនៃព័ត៌មានសំខាន់ៗពី នាយកដ្ឋានអប់រំរដ្ឋផិនស៊ីលវេនញ៉ា (PDE) ដែលផ្តល់ចម្លើយចំពោះសំណួរដែលគេឧស្សាហ៍សួរ

- **Keystone Test Features and Accommodations**: ការពន្យល់អំពីលក្ខណៈពិសេសៗ និងការជួយសម្រួលទៅតាមសេចក្តីត្រូវការនៃការប្រឡង រួមទាំងបណ្តាញតភ្ជាប់ទៅកាន់ការណែនាំអំពីការជួយសម្រួលទៅតាមសេចក្តីត្រូវការ

- **Code of Conduct for Test Takers**: អ្វីដែលអាចធ្វើ និងអ្វីដែលមិនអាចធ្វើ សម្រាប់សិស្សក្នុងអំឡុងពេលធ្វើតេស្ត

- **Electronic Devices Parent Letter**: លិខិតផ្ញើជូនក្រុមគ្រួសាររៀបរាប់លម្អិតអំពីគោលការណ៍របស់នាយកដ្ឋានអប់រំរដ្ឋផិនស៊ីលវេនញ៉ា (PDE)) និងផលវិបាកសម្រាប់ការប្រើប្រាស់ទូរសព្ទដៃ និងគ្រឿងអេឡិចត្រូនិចផ្សេងទៀត ក្នុងអំឡុងពេលធ្វើតេស្ត

ប្រសិនបើលោកអ្នកមានសំណួរអំពីការប្រឡងរបស់ក្រសួងអប់រំ សូមទាក់ទងការិយាល័យវាយតម្លៃ ស្រាវជ្រាវ និងទទួលខុសត្រូវ តាមរយៈគេហទំព័ររបស់ពួកគេ via their webform។ ប្រសិនបើលោកអ្នកមានសំណួរអំពីតម្រូវការបញ្ចប់ការសិក្សារបស់ក្រសួងអប់រំ សូមទាក់ទងការិយាល័យផ្នែកត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ និងអាជីព ដោយផ្ញើអ៊ីមែលទៅ gradreq@philasd.org ឬចូលទៅកាន់ គេហទំព័ររបស់ពួកគេ their website។

សូមអរគុណចំពោះការសហការជាមួយក្រសួងអប់រំដើម្បីគាំទ្រដល់ការលូតលាស់ និងជោគជ័យរបស់ក្មេងក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ខណៈពេលដែលការប្រឡង Keystone គ្រាន់តែជាមធ្យោបាយមួយដើម្បីវាស់ស្ទង់ការរីកចម្រើន ការប្រឡងទាំងនេះផ្តល់ព័ត៌មានសំខាន់ៗដែលយើងអាចប្រើប្រាស់ដើម្បីកែលម្អសេវាកម្មរបស់យើងដល់ក្មេង និងក្រុមគ្រួសារបន្ថែមទៀត ជូនដំណឹងអំពីការអនុវត្តផែនការយុទ្ធសាស្ត្ររបស់យើង និងជួយយើងក្នុងការស្វែងរកចក្ខុវិស័យរបស់យើង ដើម្បីរៀបចំសិស្សទាំងអស់ឱ្យស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេប្រាថ្នាចង់បាន!

ក្នុងភាពជាដៃគូ



Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា